# ១-ប្រវត្តិអ្នកតាឃ្លាំងមឿង

ប្រជុំរឿងព្រេងខ្មែរភាគ ៨ ពីទំព័រទី១ – ១៩

ទីកន្លែងអ្នកតានោះ ជាទីរហោស្ថាន មានរុក្ខជាតិតូចធំដុះព័ទ្ធជុំវិញមានមែកបែកសាខា មានម្លប់ត្រឈៃត្រជាក់ គួរឲ្យសប្បាយរីករាយអស្ចារ្យ ហើយមានសត្វបក្សីបក្សាកញ្ចៀវខ្មៀវខ្វារ ប្រចឹកគ្នាលើមែកព្រឹក្សានោះ ឮស្ទូរសំឡេងទ្រហឹង ។ បន្ទាប់អំពីរុក្ខជាតិ មានវាលស្រែព័ទ្ធជុំវិញ បើមើលអំពីចម្ងាយទៅ ឃើញរុក្ខជាតិដង្គុំត្រសុំខ្នុលខ្មៅ ដាច់ស្រយាលអំពីភូមិស្រុក ។ បណ្ដាដើមឈើទាំងអស់នៅទីនោះ មានដើមសំរោងមួយខ្ពស់ធំជាងឈើឯទៀតៗ ដុះចំពីមុខអាស្រម ។ ពីសាលាខែត្រពោធិ៍សាត់ ទៅអ្នកតានោះ ចម្ងាយប្រមាណជា ៦ គីឡូម៉ែត្រ ។ គេត្រូវចេញតាមផ្លូវថ្នល់ ពីសាលាខែត្រទៅទិសខាងលិច ប្រមាណជាពីរគីឡូម៉ែត្រ ត្រូវងាកទៅទិសខាងត្បូង កាត់ផ្លូវអេយស្មំយយាន ដល់ឃុំបាក់នឹម បែរទៅទិសខាងលិច ដល់ភូមិព្រៃកជីក ឡើងពីព្រៃកជីកងាកទៅកាន់ទិសខាងជើង ទើបដល់កន្លែងអ្នកតា ។

ជុំវិញអាស្រមអ្នកតា មានវាលស្រឡះទំនេរ នៅត្រង់ចន្លោះរុក្ខជាតិ ។ នៅពីខាងត្បូងអាស្រមជាទីវាលទុកសម្រាប់ធ្វើរោង មានបណ្ដោយ ៦០ ម៉ែត្រ ទទឹង ៤០ម៉ែត្រ ។ អាស្រមនោះធ្វើដោយឈើ ប្រក់ស្បូវមានបណ្ដោយ ៨ ម ទទឹង ៤ ម កម្ពស់ ៤ ម សសរលញ់ មិនមានជញ្ជាំងបិទបាំងទេ ។ ជុំវិញអាស្រមមានលានទំហំ ៤ ម ទុកបម្រុងឲ្យពួកអ្នកទៅធ្វើបុណ្យដើរហែប្រទក្សិណនៅពេលឡើងអ្នកតា ។ ពីខាងក្រៅទីវាលមានរបងធ្វើដោយឈើខ្លឹមព័ទ្ធជុំវិញ មានតែផ្លូវចូលពីខាងកើតមួយ និងពីខាងត្បូងមួយ ។ ក្នុងអាស្រមខាងមុខតួអ្នកតា មានរានម៉ា បណ្ដោយ ៣ ម ទទឹង ២ម កម្ពស់ ៥ តឹក ធ្វើដោយឈើ ជារានសម្រាប់ដាក់ដង្វាយអ្នកតា ខាងជើងនិងខាងត្បូងអ្នកតា មានបង្កាន់ដៃដោតដោយចាមរនិងបែមន់ធ្វើដោយឈើដែរ ។

តួអ្នកតា មិនមានរូបរាងបែបឈើ ឬ ថ្មជាតំណាងទេ គឺជាតួដីដំបូកសុទ្ធៗ ទំហំបណ្ដោយ ២ ម៉ែត្រ ទទឹង ១ ម៉ែត្រ កម្ពស់ ២ ម៉ែត្រ ដែលកើតអំពីសត្វកណ្ដៀរវាពូនលើង សន្មតថាជាតួអ្នកតាតែម្ដង នៅកំពូលនៃដំបូកមានពំនូកដី ៤-៥ ស្រួចៗបែកចេញ មើលទៅដូចជាកំពូលនគរវត្ត ។ កំពូលដីដំបូកដែលជាតួអ្នកតានេះ អ្នកស្រុកថា បើមានសត្វកណ្ដៀរពូនឡើងថ្មីទៀត សន្មតថា ចៅហ្វាយខែត្រ ឬចៅហ្វាយស្រុកនៅខែត្រ-ស្រុកនោះ នឹងត្រូវផ្លាស់ចេញ ឬខូចបុណ្យសក្តិ ដីដំបូកនេះមិនដឹងថាកើតពីត្រឹមរាជ្យស្ដេចណាទេ ពុំមានអ្នកស្រុកណាដឹងសោះ ។

ពិធីបុណ្យឡើងអ្នកតា- បុណ្យនេះជាបុណ្យទំនៀមទម្លាប់ជាប់យូរមកហើយរបស់អ្នកស្រុក និងពួកសាលាស្រុក តែងធ្វើតែរាល់ៗឆ្នាំ ក្នុងខែពិសាខ ថ្ងៃសៅរ៍ ។ តែមិនកំណត់ជាខ្នើតឬរនោចទេ រើសយកតែថ្ងៃសៅរ៍ពេលធ្វើលុះណាតែមានសេចក្ដីបង្គាប់ អំពីចៅហ្វាយស្រុកបាកាន ប្រាប់ទៅមេឃុំ មេស្មឹង អាចារ្យវត្តនិងបណ្ដារាស្ត្រទាំងអស់ឲ្យដឹងជាមុន ដើម្បីមកជួបជុំ ជួយធ្វើរោងក្រសាល និងរៀបចំបោសច្រាសទីកន្លែងឲ្យស្អាតល្អ សម្រាប់ព្រះសង្ឃ និងមន្ត្រីរាជការក្នុងខែត្រ ។ ទំនៀមនេះជាប្រពៃណីរបស់អ្នកស្រុក ។ កាលពីថ្ងៃទី ១៨ មិថុនា ឆ្នាំ ១៩៤៩ ពេលចាប់ផ្ដើមបុណ្យត្រូវជួបជុំមេឃុំទាំងអស់ មេស្មឹង អាចារ្យវត្ត និងបណ្ដារាស្ត្រ

នៅទីកន្លែងអ្នកតា ។ ពេលម៉ោង ៦ ល្ងាច មេស្មឹងអុជទៀនធូបទោងជម្រាបអ្នកតា :" ថ្ងៃនេះ យើងខ្ញុំជាកូនចៅមកជួបជុំគ្នា ធ្វើបុណ្យនៅទីនេះជូនលោកតា សុំឲ្យយើងទាំងអស់គ្នា បានសុខសប្បាយ "រួចគេលេងភ្លេងថ្វាយ មានភ្លេងខ្មែរ ភ្លេងពិណពាទ្យ ភ្លេងឆៃយ៉ាំ ភ្លេងត្រពាំងទា តាមធម្មតា ឮសូរភ្លេងប្រគំទ្រហឹងអឺងកងរំពងព្រៃ មនុស្សចាស់ក្មេង រទេះគោ រទេះក្របី មកពីស្រុកឆ្ងាយៗ មកជួបជុំគ្នាមីរដេរដាសនៅទីនោះ ។ ម៉ោង ៩ យប់ ជួបជុំគ្នាសូត្រនមស្ការថ្វាយបង្គំព្រះ រួចនិមន្តព្រះសង្ឃ ១០ អង្គចម្រើនព្រះបរិត្ត ។ លុះព្រឹកឡើង ថ្ងៃអាទិត្យ ១៩ ខែឆ្នាំដដែល ពេលម៉ោង ៨ កន្លះ ពួកមន្ត្រីរាជការសាលាខេត្រ សាលាស្រុកគ្រប់តំណែង អញ្ជើញទៅជួបជុំគ្នានៅកន្លែងនោះ ហើយចូលទៅឈរនៅខាងត្បូងអ្នកតា មេស្មឹងអុជទៀនធូបជូនអស់លោកដោតថ្វាយអ្នកតា ដោយសេចក្តីគោរព រួចមេស្មឹងបង្គាប់ឲ្យលើកគ្រឿងតង្វាយ មករៀបនៅលើរាន ចំពោះមុខអ្នកតា ។

តង្វាយអ្នកតាគឺ :

1. - កន្ទេលក្រហម ខ្នើយ
2. - សំពត់សក្រាលពីលើកន្ទេល
3. - ស្លាធមិដូង ១ គូ (ដោតម្លូ ៥ ស្លា ៥ ធូប ៣ សរសៃ)
4. - ក្បាលជ្រូក ១ គូ មានទាំងកន្ទុយដាក់នៅមាត់ផង ។
5. - ផ្តិលទឹកអប់ ១ គូ ឈើស្ទន់ ១
6. - ពានស្លាបារីមួយគូ
7. - ដបស្រា ១ គូ មានទាំងពែង
8. - ចេកនួន ២ ស្និត តម្កល់លើចានទាប
9. - បង្អែម ២ ស្តក
10.- ចំអាម ២ ស្តក
11.- កន្ទោងស្លឹកចេក ១ គូ
12.- មាន់ស្ងោរ ១គូ
13.- ស្នែងសត្វទន្សោង ១ គូ

រណ្តាប់តង្វាយទាំង ១៣ មុខនេះ មានគូគ្រប់ទាំងអស់ សម្រាប់ដាក់ឆ្វេងស្តាំ ក្រៅអំពីតង្វាយ ១៣ មុខនេះ មានតង្វាយដែលអ្នកស្រុកថ្វាយថែមទៀតបរិបូរណ៍ត្រៀបត្រា ដាក់នៅរាននោះ ។ គេអុជទៀនធូបចែកគ្នាកាន់ ដើរហែប្រទក្សិណជុំវិញអាស្រម ជាការគោរពចំពោះអ្នកតា និងនឹកគុណដល់លោកឧកញ៉ាសេនាបតីមឿងដែលស៊ូប្តូរជីវិត យកឈាមក្រាលផែនដី មានកេរ្តិ៍ឈ្មោះតាំងពី គ. ស. ១៥១៦ ដរាបមកដល់សព្វថ្ងៃនេះទើបអ្នកស្រុកសន្មតហៅថា អ្នកតាឃ្លាំងមឿង ។ គេរើសរកមនុស្សឲ្យមានរូបរាងប៉ុនៗគ្នា ២ នាក់ សម្រាប់ពាក់ស្នែងសត្វទន្សោង១ តែងតួស្លៀកសំពត់ផាមួងចងក្បិន ខ្លួនទទេ អ្នករាំ ២ នាក់ទៀត ធ្វើព្រានព្រៃម្នាក់ស្ពាយកាំភ្លើង ម្នាក់ស្ពាយបាយសំណុំដើរតាមពីក្រោយ ស្លៀកពាក់ដូចគ្នានឹងអ្នកពាក់ស្នែងទន្សោងដែរ លុះហែ ៣ ជុំរួចហើយ គេលេងភ្លេងរាំស្នែងទន្សោង ភ្លេងនោះឈ្មោះ " ភ្លេងភ្លាំង " អ្នករាំចាប់ពាក់ស្នែងរួច ក្រាបថ្វាយបង្គំអ្នកតា ៣ ដង ឡើងរាំបែរឆ្វេងរៀងខ្លួន មកជួបគ្នាគ្រប់គ្នាម្តង ដល់គម្រប់ ៣ ដង វារនឹងដី

អួតដាក់គ្នា ជល់គ្នាដូចគ្នាដូចសត្វមែនៗ ព្រានព្រៃដើររកស្នាមជើងសត្វទន្សោង ដើបឱនៗ ដើម្បីតាមបាញ់ ។ មនុស្សឈរមើលពេញទីវាល នៅមុខអាស្រមអ្នកតានោះ ។

## ទំនុកច្រៀង

១- បងដើរព្រៃស្តុក តត្រុកព្រៃស្បាតៗ

ដើរកាត់ព្រៃញាត លេចវាលចូលព្រៃ ។

២- ឡើងភ្នំចុះភ្នំ ថ្មដាធំៗ

ល្បាស់ព្រេចលាស់ខ្ចីៗ ទន្សោងគោបា

កៀងញីឃ្មាតខ្ចីៗ ល្បាស់ព្រេចលាស់ខ្ចី

ស្រណោះខែពិសាខៗ ។

៣- កន្ទ្រែតៗអើយ ទន្សោងគោបា

លេបបន្លាបន្លាជើងភ្នំ លេបក្រមុំទាំងមូលៗ ។

៤- ជំនោរខ្យល់បក់ ត្រជាក់ខ្យល់ជូន

កាប់ឫស្សីចងក្បូន ជូនប្អូនទៅស្រុកៗ ។

៥- កន្សែងបងបាត់ បងមិនស្តាយ

បំណាច់ប្អូនឃ្លាតឆ្ងាយ បងស្តាយតែប្អូនស្រីៗ ។

ពួកអ្នកភ្លេងច្រៀងដរាប លុះព្រានទាំងពីរនាក់ ឃើញសត្វទន្សោងជល់គ្នាជាប់ ក្រាបវៀងខ្លួន លបបាញ់បាន ទើបដោះយកស្នែងសត្វទន្សោងទាំងពីរ ទៅតម្កល់នៅកន្លែងដើមវិញ (លេងកន្លះម៉ោងចប់) មេស្នឹងចាប់គ្រឿងតង្វាយគ្រប់មុខដាក់កន្ទោង ចាក់ស្រា ដោតធូប ៣សរសៃ រួចនិយាយបួងសួងថា "ថ្ងៃជាថ្ងៃជាពេលាល្អ យើងខ្ញុំមកជួបជុំគ្នាធ្វើបុណ្យឧទ្ទិសកុសលចំពោះលោកតា មឿង ដែលមានគុណចំពោះស្រុកខ្មែរ សូមលោកតាឲ្យពរសព្វសាធុការដល់ប្រទេសកម្ពុជាឲ្យបានសុខសប្បាយ សូមឲ្យព្រះករុណាជាម្ចាស់ជីវិតលើត្បូង សោយសេចក្ដីសុខក្នុងរាជសម្បត្តិ សូមឲ្យបានសេចក្ដីសុខសប្បាយ អស់កាលជាអង្វែងវៀងទៅ សូមឲ្យទឹកភ្លៀងបង្អោរចុះមក ឲ្យបានសព្វផែនដីប្រទេសកម្ពុជា ឲ្យស្រុកសម្បូណ៌សប្បាយ កុំឲ្យមានភ័យអន្តរាយអ្វីឡើយ ។ បួងសួង ៣ ដងស្រេចហើយ យកកន្ទោងទៅដាក់ក្រោមដើមសំរោង នៅមុខអាស្រម ។ រួចលើកគ្រឿងតង្វាយទាំងអស់ចេញ ។ និមន្តព្រះសង្ឃ ៥ អង្គបង្សុកូល ពួកឧបាសកសូត្រឧទ្ទិសផល មេស្នឹងយកទឹកអប់ទៅលើដំបូក ដែលជាតួអ្នកតា ពួកអ្នករាជការ ចៅហ្វាយខេត្រ ចៅហ្វាយស្រុក និងមន្ត្រីតូចតាចគ្រប់ដំណែង បាចទឹក ១ ផ្តិលៗ ម្នាក់ រួចអញ្ជើញទៅរាប់បាត្រនៅវាលមុខរោងព្រះសង្ឃ ។

ម៉ោង ១១ រៀបភោជនាហារ លៀងពួកមន្ត្រីសាលាខេត្រសាលាស្រុកធំតូចគ្រប់ដំណែងដោយវត្ថុដ៏ឧត្តម ពីសាសប្បាយ មានភ្លេងត្រពាំងទា មានប្រុសស្រីច្រៀងតគ្នាជូនអស់លោកស្ដាប់ដល់ម៉ោង ១២ ជាការបង្ហើយកិច្ច ។

អំពីទំនៀមរាំពាក់ស្នែងទន្សោង និងពាក់កន្ទុយក្ងោកនេះ មានសេចក្ដីដំណាលថា ក្នុងកាលដ៏កន្លងយូរមកហើយ (សករាជ និងរាជ្យណាមិនប្រាកដ) មានដើមឈើ ១ ដើមនៅក្នុងស្រុកពោធិ៍សាត់ ថ្ងៃមួយព្រាន ២ នាក់ មានឈ្មោះមិនប្រាកដនាំគ្នាចូលព្រៃ ដើម្បីបរបាញ់សត្វតាមទម្លាប់របស់ខ្លួន ។ លុះចូលទៅដល់ដើមឈើនោះ ឮសូរសំឡេងសត្វកន្លង់ពីរោះ ហាក់ដូចសូរសំឡេងភ្លេងដូរ្យតន្ត្រីលាន់ឮរងំ ដូចជាសំឡេងទ្រសាយដៀវ ឃើញសត្វទន្សោង ១គូ លោតកញ្ឆេងជល់គ្នាលេង ដូចគេរាំ ។ មានសត្វខ្លា ១ គូក្រាបនៅទីនោះ វាគោះកន្ទុយហាក់ដូចគេវាយស្គរ ។ មានសត្វក្ងោក ១ គូ កាងស្លាប បើកកន្ទុយ លោតចុះលោងឡើង ហាក់ដូចគេចាក់ត្លុកចាក់ក្បាច់ ។ ព្រានទាំងពីរនាក់លាន់មាត់ថា " ឱហ្ន ! សត្វទាំងនេះប្លែកចម្លែកអស្ចារ្យ សូរសំឡេងសត្វកន្លង់ដូចសំឡេងដូរ្យតន្ត្រី សត្វទន្សោងនិងសត្វក្ងោក ដូចជាអ្នករាំចាក់ក្បាច់ សត្វខ្លាដូចជាអ្នកវាយស្គរបន្ទរតាម យើងគួរប្រកបធ្វើជាភ្លេងលេងតាមសត្វទាំងនេះ ទុកជាកេរ្ត៍ឲ្យកូនចៅងក្រោយ។ ប្រវត្តិអ្នកតាឃ្លាំងមឿង

ក្នុងអតីតកាលកន្លងទៅ ក្នុងរាជ្យព្រះចន្ទរាជាស្ដេចគង់នីបន្ទាយលង្វែក (គ. ស. ១៥០២) កាលជាន់នោះស្រុកខ្មែរ ជាស្រុកចំណុះសៀមនៅឡើយ តែងនាំសួយសារអាករឡើងទៅស្រុកសៀម ព្រះចៅសៀមចាត់ព្រះរាជបុត្រមួយព្រះអង្គ មានព្រះនាមមិនប្រាកដ ឲ្យមកនៅស្រុកខ្មែរដើម្បីមើលការខុសត្រូវ ធ្វើជាអ្នកត្រួតត្រាខាងពន្ធអាករគ្រប់យ៉ាង ក្រែងស្ដេចស្រុកខ្មែរមានចិត្តមិនត្រង់ បំបាត់សួយសារអាករយកទៅមិនអស់ ឬមួយក្រែងស្ដេចខ្មែរមានគំនិតក្បត់ មានចិត្តមិនត្រង់នឹងរាជការ ដោយប្រការណាមួយ ទើបប្រើព្រះរាជបុត្រពេញព្រះហឫទ័យមកនៅ ដើម្បីជំនួសព្រះនេត្រព្រះអង្គ ចំណែកព្រះរាជបុត្រមានចិញ្ចឹមសត្វត្មាតមួយ ត្មាតនោះមានមារយាទ ចេះដឹងប្រហែលមនុស្ស ជាសត្វខុសពីសត្វដទៃធម្មតា ចេះស្រឡាញ់ម្ចាស់ ប្រើនាំសារទៅមក រវាងស្រុកខ្មែរនិងស្រុកសៀមបានដោយស្ទាត់ ។ ថ្ងៃមួយ ព្រះចន្ទរាជានឹកព្រួយព្រះទ័យថា ព្រះចៅលោកមិនទុកព្រះហឫទ័យនឹងយើងហើយ បានជាលោកចាត់ព្រះរាជបុត្រឲ្យមើលការផ្ទាល់ ណាមួយព្រះរាជបុត្រនោះ មានការរំលោភបៀតបៀន មិនមានសេចក្ដីកោតក្រែង បង្គាប់ឲ្យនាំសួយឡើងនគរខ្លួនហួសហេតុ ទ្រង់តូចព្រះហឫទ័យខ្លាំង អត់ទ្រាំពុំបាន ក៏បង្គាប់ពួកពេជ្ឈឃាដចាប់រាជបុត្រស្ដេចសៀម យកទៅសម្លាប់ចោលក្នុងព្រៃក្នុងពេលយប់ ។ ឯសត្វត្មាត លុះព្រឹកឡើងមិនឃើញព្រះរាជបុត្រជាម្ចាស់របស់វាៗហើរចុះ ហើរឡើងរកឃើញខ្មោចនៅក្នុងព្រៃ ត្មាតឃើញព្រះទម្រង់ វាស្គាល់ច្បាស់ជាម្ចាស់វា ក៏ចឹកពាំព្រះទម្រង់ទៅស្រុកសៀម ថ្វាយព្រះបិតា ។ ព្រះចៅទតឃើញព្រះទម្រង់ ទ្រង់យល់ថា ព្រះរាជបុត្ររបស់ព្រះអង្គដល់ទិវង្គតហើយ រឿងនេះពិតស្ដេចស្រុកខ្មែរសម្លាប់ ។ ទ្រង់ក្រោធខ្លាំងណាស់ កោះប្រជុំពួកសេនាបតីមួយរំពេច មានព្រះបន្ទូលប្រាប់តាមរឿង រួចបង្គាប់ឲ្យលើកទ័ព មកសងសឹកស្ដេចស្រុកខ្មែរវិញ ហើយមានព្រះបន្ទូលថា ត្រូវតែសម្លាប់ព្រះចន្ទរាជាព្រមទាំងញាតិសាច់សាលោហិត ទាំងពួកសេនាបតីហើយរិបជាន់យកទ្រព្យសម្បត្តិ និងកៀរពួកបណ្ដារាស្ត្រមកស្រុកសៀមកុំឲ្យសល់ ។ ពួកកងទ័ពក៏ចេញមក មកដល់បន្ទាយលង្វែក ចូលឡោមព័ទ្ធចាប់ព្រះចន្ទរាជាសម្លាប់ ព្រមទាំងព្រះញាតិ ។ ចំណែកព្រះម្នាង ប៉ែន ជាស្នំ ក៏ភៀសខ្លួនរួចពីគ្រោះថ្នាក់ជាមួយនឹងសេនាបតី មឿង ព្រមទាំងភរិយានឹងបុត្រ ៤នាក់ទៀត ។ ពួកកងទ័ពសៀម

កៀរមនុស្សអំពីស្រុកខ្មែរ ដោយទាំងព្រះម្នាង ប៉ែន ទៅជាមួយផង ទាំងព្រះរាជទ្រព្យមានវិញ្ញាណឥតវិញ្ញាណ ។ ចំណែកមេដំរីសមួយ មានកូននៅក្នុងពោះ ឈ្មោះជំទាវប៉ោលប៉ៃ ដែលជាព្រះទីន័ងដ៏ប្រសើរ ក៏ត្រូវកងទ័ពសៀមកៀរយកទៅដែរ ។ ពួកសៀមជាន់នោះមានសេចក្ដីព្យាបាទ ធ្វើបាបខ្មែរអស្ចារ្យណាស់ ចាប់មនុស្សដោតស្លឹកត្រចៀកដឹកយកទៅដូចជាសត្វធាតុ ស្រីណាមានកូនខ្ចី ចាប់ច្រកការុងឲ្យដំរីជាន់ វៀរលែងតែមានកូននៅក្នុងពោះ ។ លុះទៅដល់ស្រុកសៀម នាំសេចក្ដីទៅថ្វាយព្រះចៅដោយសព្វគ្រប់ ។ ដោយសេចក្ដីសងសឹកបានសម្រេចដូចប្រាថ្នា ព្រះចៅទ្រង់បង្គាប់ឲ្យពួកខ្មែរទាំងអស់ ទៅនៅមួយក្រុម ជិតក្រុងហើយសន្មតឲ្យឈ្មោះថា "ក្រុមខ្មែរអ្នកគ្រួ " ។

ព្រះម្នាង ប៉ែន ហាក់ជាស្រីមានបុព្វវាសនា ទុកណាជានាងទទួលគ្រោះថ្នាក់ ដោយសៀមកៀរយកទៅយ៉ាងនឹងក៏ដោយ នាងគង់នៅជាស្រីប្លែកអំពីស្រីឯទៀតៗ ។ ដោយអំណាចកូនដែលនៅក្នុងគភ៌ ជាកូនមានឥទ្ធិឫទ្ធីមានបុណ្យ ក៏បណ្ដាលឲ្យអ្នកផងជិតខាង មានចិត្តទោរទន់ រាប់អានស្រឡាញ់ ជួយឧបត្ថម្ភ ជួយយកអាសានាងគ្រប់យ៉ាង ។ លុះនាងមានគភ៌គ្រប់ខែដប់ ក៏ប្រសូតបុត្រមកដោយសុខសប្បាយ អ្នកជិតខាងទាំងប្រុសទាំងស្រី ជួយថែទាំផ្ដល់ទឹកក្ដៅទឹកត្រជាក់ អ្នកណាក៏មកមិនមានខាន ដោយអំណាចគុណបុណ្យតេជះបារមីនៃទារកនោះ ។ លុះប្រសូតបាន ៣ ថ្ងៃ ពួកក្រុមញាតិមូលមាត់គ្នា ឲ្យឈ្មោះកូននោះថា ឧទេន ។

ចំណែកមេដំរីដែលជាព្រះទីន័ង ក៏កើតកូនក្នុងថ្ងៃដំណាលទារកនោះដែរ តែមេដំរីនោះ ផ្ដាច់ខ្សែទន្លីង ទៅកើតកូននៅក្នុងព្រៃឆ្ងាយ លាក់មិនឲ្យអ្នកណាមួយដឹងឡើយ ដរាបដល់៣ថ្ងៃ ទើបនាំកូនមកកាន់ទីកន្លែងដើមវិញ ។ កូនដំរីនោះមានពណ៌សម្បុរ ព្រមទាំងរូបរាងល្អប្លែក អំពីដំរីធម្មតា អ្នករក្សាដំរីនាំដំណឹង ទៅក្រាបទូលព្រះចៅគ្រប់សព្វ ព្រះចៅពេញព្រះហឫទ័យណាស់ ។

ដំណាលពីកុមារឧទេន លុះបានអាយុប្រាំឆ្នាំ ដឹងសេចក្ដីខុសត្រូវខ្លះនឹកភ្នករកបិតា សួរម្ដាយថា "ឪពុកខ្ញុំទៅណា ពុំដែលឃើញ ក្មេងគេឯទៀតមានម្ដាយ-ឪពុក ខ្ញុំមិនឃើញមានឪពុកដូចគេ?” ម្ដាយកាលបើឮកូនសួរដូច្នោះ នាងណែនក្នុងទ្រូង អួលអាក់ខ្លោចផ្សា និយាយប្រាប់កូនមិនរួច ក៏និយាយបន្លែបន្លប់វៀងវៀះទៅ កុំឲ្យកូនសួរទៀត ពីព្រោះខ្លាចក្រែងរឿងនោះ មិនជិតដឹងទូទៅ នឹងដល់នូវសេចក្ដីអន្តរាយនៃជីវិត ។ កូនចេះតែសួរញយ នាងក៏និយាយបង្វេះពង្វាងមិនឲ្យសួរបាន ដរាបដល់កូននោះ អាយុ ១២ ឆ្នាំ ។ ថ្ងៃមួយនាងនឹកថា កូននេះខានប្រាប់ពុំបាន ក៏នាំកូនទៅកាន់ទីស្ងាត់តែពីរនាក់ ដំណាលរឿងរ៉ាវតាំងពីដើមរហូតដល់ចុងកូនស្ដាប់បាន យល់សេចក្ដីសព្វគ្រប់ ប្រាប់ម្ដាយឲ្យអត់ទ្រាំសិនចុះ កូននឹងគិតរកមធ្យោបាយណាមួយ ដើម្បីនឹងវិលទៅនគរវិញ ។ ចំណែកកុមារឧទេន ចាប់ដើមតាំងពីថ្ងៃដែលបានស្ដាប់ពាក្យម្ដាយមក ក៏ខំស្វែងរៀនសូត្រវិជ្ជាគ្រប់យ៉ាង មានអក្សរជាដើមឧទេនជាកុមារឆ្លាតវាងវៃ អង់អាចប្លែកពីកុមារធម្មតា។

ថ្ងៃមួយកុមារឧទេន ចូលទៅសេពគប់នឹងពួកហ្មដំរី សុំខ្លួនជាអ្នកបម្រើបោសច្រាសរោងដំរី ដើម្បីរៀនវិជ្ជាខាងហ្មដំរីឲ្យស្ទាត់ ថ្ងៃមួយព្រះចៅស្ដេចយាងមកទតរោងដំរី ឃើញកុមារនោះជួយធ្វើនេះធ្វើនោះ ដោយយកចិត្តទុកដាក់រហ័សរហួនវាងវៃ មានព្រះបន្ទូលសួរថា ក្មេងនេះ មកពីណា ហ្មដំរីក្រាបទូលតាមដំណើរដោយសព្វគ្រប់ ទ្រង់ពេញព្រះហឫទ័យមានព្រះបន្ទូលប្រាប់ថា ចូរមើលក្មេងនេះផង ។ ចាប់ដើមពីថ្ងៃនោះមកកុមារខំយកចិត្តទុកដាក់ ធ្វើការដោយហ្មត់ចត់ បោសប្រមូលអាចម៍ដំរី ដុតបំពក់ជាជីរ ដើម្បីយកទៅដាំស្ពៃស្ពៃក៏មានគុម្ពធំប្លែក ចម្លែកអំពីស្ពៃអ្នកស្រុកធម្មតា ។ លុះស្ពៃនោះធំល្មមដក កុមារឧទេនដកយកទៅលាង

យ៉ាងស្អាត រែកយកទៅថ្វាយព្រះចៅ ទ្រង់ទតឃើញមានព្រះបន្ទូលថា "នែ! កុមារឯងបានស្ដែនេះមកពីណាប្លែកពីស្ដែធម្មតា" កុមារក្រាបទូលតាមដំណើរសព្វគ្រប់ ព្រះចៅទ្រង់ប្រទានរង្វាន់នឹងមុខងារជាអ្នកត្រួតត្រាភ្នាក់ងារខាងដំរី ។

ដំរី ជាកូនមេដំរីឈ្មោះជំទាវប៉ោលប៉ៃ ដែលជាទីន័ងដ៏ប្រសើររបស់ព្រះចៅ ក៏ស្រាប់តែចុះប្រេង មានកិរិយាខុសប្រក្រតី កាចសហាវមិនព្រមស្ដាប់បង្គាប់ ព្រិចហ្មស្លាប់ មិនមានអ្នកឯណាមួយអាចដឹកបាន ថែមទាំងធ្វើបាបអ្នកស្រុក បោចរោចផ្ទះសម្បែងផ្អើលជ្រួលច្របល់រត់ខ្ចាត់ខ្ចាយចោលទីលំនៅរៀងៗខ្លួន ។ ពួកអ្នកគង្វាលដំរី នាំសេចក្ដីទៅទូលព្រះចៅៗទ្រង់ចាត់ការឲ្យស៊ើបសួររក អ្នកណាដែលអង់អាចក្លាហានហ៊ានទៅចាប់ដំរីនោះបាន ។ ពេលនោះកុមារឧទេនឆ្លើយថា ខ្ញុំហ៊ានទទួលការចាប់ដំរីនោះឲ្យបាន ទើបទ្រង់ប្រគល់ការទៅកុមារឧទេន ចាត់ការយ៉ាងណាឲ្យតែចាប់បានព្រះទីន័ងនោះបាន ។ ឧទេនបង្គាប់ឲ្យប្រមូលដំរី ៥០០ មក ដើម្បីនឹងរើសយកដំរីណាគួរមកធ្វើផ្ទាក់បាន ទើបរើសយកមេដំរីសឈ្មោះជំទាវប៉ាល់ប៉ៃ ពេលចេញទៅចាប់ កុមារឧទេនបង្គាប់ឲ្យរៀបពិធីបួងសួងសែនព្រេនអ៊ឹកធឹក ។ អ្នកស្រុកផ្អើលមកមើលគឹកកង ពាសពេញមីរដេរដាស់ លុះសែនព្រេនរួច កុមារឧទេនបង្គាប់ឲ្យចេក ៣ ស្និត អំពៅ ៣ បាច់ ពេលទៅដល់ ព្រះទីន័ងស្ទុះមករក ហាក់ដូចជាប្រុងនឹងព្រេច តែបែរទៅជាក្រាបថ្វាយបង្គំវិញ ដោយអំណាចតេជះបុណ្យបារមីនៃឧទេនៗនិយាយទូន្មានប្រដៅថា "ទីន័ងឯងតាំងពីថ្ងៃនេះទៅទៅ លះបង់មារយាទអាក្រក់ចេញទៅ ត្រូវធ្វើឲ្យស្លូតល្អដូចដើម" ឲ្យចេកនិងអំពៅស៊ីរួច និយាយថា "ឯងទៅតាមយើង" ថាតែប៉ុណ្ណោះ ស្រាប់តែដំរីដើរតាមទៅដោយស្រួល ឥតបាច់ចាប់ចងអ្វីឡើយហាក់ដូចជាហ្មចាស់យូរមកហើយ ។

ចាប់ដើមតាំងពីថ្ងៃដែលទៅយកព្រះទីន័ងមក ព្រះចៅទ្រង់ប្រទានរង្វាន់ឲ្យឧទេននិងប្រទានងារថា ជ័យអស្ចារ្យ ជាសេនាខាងទ័ពដំរីនិងខាងទាក់ដំរីព្រៃ ។ ពួកអ្នករាជការទទួលស្គាល់ ខ្លាចអំណាចឧទេនថាជាអ្នកមោះមុត ស្ទាត់ជំនាញខាងហ្មដំរី សូម្បីតែពេលចេញទាក់ដំរីព្រៃម្ដងៗមិនចាំមានគ្នាច្រើនប៉ុន្មាន ក៏ទៅទាក់បានដែរ ហាក់ដូចជាហៅមកបាន ព្រះចៅទ្រង់ពេញនិងទុកព្រះហឫទ័យលើជ័យអស្ចារ្យ ប្រហែលគ្នានឹងព្រះរាជបុត្ររបស់ព្រះអង្គ ។

លុះដល់អាយ ១៦ ឆ្នាំ ជ័យអស្ចារ្យក្នក់នឹកដល់បំណងដើម ក៏រំពឹងគិតរកឧបាយណាមួយ នឹងដោះខ្លួនចេញអំពីកណ្ដាប់សៀម ហើយទៅនៅស្រុកខ្មែរ សោយរាជ្យស្នងព្រះបិតា និងនាំយកមនុស្សអំពីស្រុកសៀមទៅស្រុកខ្មែរវិញ ព្រមទាំងទ្រព្យសម្បត្តិមានវិញ្ញាណឥតវិញ្ញាណទៅឲ្យអស់អំពីស្រុកសៀម ឲ្យបានសម្រេចដូចសេចក្ដីបំណង ។

ទើបដើរនយោបាយចាត់មនុស្ស ១៥ នាក់ ដែលជាមនុស្សទុកចិត្តស្និទ្ធស្នាលដូចបងប្អូនបង្កើត ធ្វើជាលនិងឈើជើងដំរី ឲ្យយកជាលច្រកអាចម៍ដំរីញាត់ឲ្យណែន ទុកឲ្យស្ងួត ចាក់វាយតាមស្នឹងឬផ្លូវ យកឈើជើងដំរីដើរសង្កត់ជាស្នាមដាន ដូចជាជើងដំរីដើរមែនៗ ដើម្បីឲ្យស្រុកឃើញ ហើយនាំព័ត៌មាននោះក្រាបទូលព្រះចៅៗ នឹងទ្រង់ចាត់សេនាជ័យអស្ចារ្យខ្លួន ទៅតាមទាក់មិនខាន ម្យ៉ាងទៀត ដើម្បីឲ្យពលដែលព្រះចៅចាត់ឲ្យទៅជាមួយ ជឿជាក់ក្នុងចិត្តថា ជាដានដំរីពិតមែន ។

ចំណែកអ្នកស្រុក លុះឃើញដានជើងដំរីនិងអាចម៍ធំៗ អណ្ដែតតាមទឹកមកដូច្នោះ ក៏នាំសេចក្ដីនោះទៅក្រាបទូលព្រះចៅៗ ទ្រង់ប្រើជ័យអស្ចារ្យទៅតាមទាក់ដំរីព្រៃ ដែលមានដានជើងធំនោះ ។ ជ័យអស្ចារ្យក្រាប

ទូលថា សូមព្រះមេត្តាប្រោស បើទ្រង់សព្វព្រះទ័យ ចង់បានដំរីធំបែបនោះ លុះតែមានគ្នាច្រើន នឹងដំរីធ្នាក់ក៏ច្រើន ហើយឲ្យមនុស្សដែលទៅជាមួយទូលព្រះបង្គំទាំងប៉ុន្មាន ស្តាប់បង្គាប់ទូលបង្គំ ទើបធ្វើការនោះបានពេលចេញទៅ សូមព្រះអង្គមេត្តាអនុញ្ញាតឲ្យធ្វើពិធីបួងសួងផងឲ្យមានជោគជ័យ ។ ព្រះចៅទ្រង់អនុញ្ញាតគ្រប់សំណូមពរ ប្រគល់ការនោះឲ្យជ័យអស្ចារ្យ តាមត្រូវការ ធ្វើបែបណាៗ ស្រេចនៅលើជ័យអស្ចារ្យចុះ ។ លុះរៀបធ្វើពិធី ព្រះចៅប្រទានព្រះខ័នសឹកឲ្យអំណាចពេញ បើឈ្មោះណាមិនស្តាប់បង្គាប់ ត្រូវសម្លាប់បាន ។ លុះចេញទៅបានចំនួន ១៥ថ្ងៃ ដល់ពាក់កណ្តាលផ្លូវមកស្រុកខ្មែរ ជ័យអស្ចារ្យធ្វើសារទៅក្រាបទូលព្រះចៅវិញថា "សូមទ្រង់មេត្តាប្រោស ទូលបង្គំជាខ្ញុំតាមទាក់ដំរីធំនោះ កាន់តែឃើញដានកៀកហើយ តែអស់ស្បៀង សូមព្រះអង្គមេត្តាប្រោសព្រះរាជទាន បញ្ជូនមកឲ្យឆាប់ ដើម្បីនឹងធ្វើការឲ្យបានសម្រេចដូចបំណង" ។

ព្រះចៅទ្រង់ព្រះរាជទានតាមសេចក្តីសុំដោយរួសរាន់ ដោយបំណងចង់បានដំរីនោះពេក ភ្លេចគិតអំពីការបង់ខាតព្រះរាជទ្រព្យ ឬ សង្ស័យដោយហេតុណាមួយឡើយ ។

ជ័យអស្ចារ្យ លុះបានទទួលស្បៀងបន្ថែមអំពីព្រះចៅ ក៏បន្តដំណើរទៅទៀត ចំនួន១៥ថ្ងៃ ក្រោយមក ក៏បានដល់ស្រុកបាត់ដំបងដែលជាដីខ្មែរ ។ មានអ្នកស្រុកជិតឆ្ងាយគ្រប់តំបន់រត់មកចុះចូល ថ្វាយខ្លួនជាពលសេនាព្រមទាំងសេនាចាស់ម្នាក់ ធ្លាប់បម្រើព្រះវរបិតាឈ្មោះ មឿងនិងកូនប្រុស៤ នាក់ បានចូលមកថ្វាយខ្លួនដែរក៏មានមនុស្សច្រើនល្មមតទល់នឹងព្រះចៅសៀមបាន ។ ជ័យអស្ចារ្យក៏សរសេរសំបុត្រចងនឹងកដំរីប្រើឲ្យទៅអញ្ជើញម្តាយមកស្រុកខ្មែរ រួចចងកូបជំទាវប៉ាល់ប៉ៃឲ្យទៅទទួលម្តាយ ។ មេដំរីទៅដល់ទីកន្លែងម្តាយ ពេលពាក់កណ្តាលអធ្រាត្រ មេដំរីវាទម្លាក់បំពង់ ៣ ដង ម្តាយភ្ញាក់ នឹកស្មានថាកូនត្រឡប់មកវិញ ក៏អុជភ្លើងបំភ្លឺមើល តែមិនឃើញកូនឃើញតែសំបុត្រ មើលដឹងសេចក្តីសព្វគ្រប់ រៀបដំណើរឡើងជិះមេដំរីយ៉ាងប្រញាប់ខំស្រូតឲ្យជួបនឹងកូននៅស្រុកបាត់ដំបង ។ ទើបជ័យអស្ចារ្យប្រកាសខ្លួនឲ្យអ្នកស្រុកដឹងច្បាស់ថា ខ្លួនហ្នឹងហើយជាព្រះបុត្ររបស់ព្រះចន្ទរាជា គង់នៅបន្ទាយលង្វែក ឥឡូវនេះវិលមកគ្រងរាជ្យស្នងព្រះបិតា ។ រឿងនេះមិនបាត់ស្ងាត់ ជ្រាបដល់ព្រះចៅសៀម ទ្រង់ព្រះពិរោធយ៉ាងខ្លាំងពន់ពេក នឹកតូចព្រះទ័យក្រៃលែង ទ្រង់ប្រជុំពួកសេនាយោធាមកប្រាប់មកប្រាប់ថា ជ័យអស្ចារ្យ ប្រើឧបាយកល បោកបញ្ឆោតយកព្រះខ័នសឹកព្រមទាំងទ្រព្យមានវិញ្ញាណឥតវិញ្ញាណ រត់ទោស្រុកខ្មែរ ហេតុនេះ ត្រូវលើកទ័ពតាមទៅដណ្តើមមកវិញឲ្យបាន ហើយចាប់ជ័យអស្ចារ្យ សម្លាប់ឲ្យផុតពូជព្រះចន្ទរាជា ព្រមទាំងពួករាជការទាំងប៉ុន្មានកុំឲ្យសល់ ។

ជ័យអស្ចារ្យបានដំណឹងច្បាស់ថាព្រះចៅលើកទ័ពមកតាមដូច្នោះ ទ្រង់ជំនុំនឹងសេនាបតីថា ឥឡូវពលសេនាយើងនិងគ្រឿងអាវុធយុទ្ធភណ្ឌរបស់យើងមិនបរិបូរណ៍ តើអ្នករាល់គ្នាគិតរកឧបាយកលបែបណា ឲ្យមានជ័យជម្នះ ពេលនេះ ពលសេនាទាំងអស់មិនមានអ្នកណាមួយហ៊ានឆ្លើយទទួលអះអាងសោះ មានតែសេនាមឿងឆ្លើយធានាអះអាង ហ៊ានតទល់នឹងទ័ពសៀម ដោយឧបាយមួយដ៏ចម្លែក គឺហ៊ានប្តូរជីវិត ដើម្បីនឹងទៅកែនពលខ្មោច ធ្វើជាទ័ពច្បាំងនឹងពលសៀម ។ ទើបបង្គាប់ឲ្យជីករណ្តៅទំហំ ៤ម៉ែត្រ ជម្រៅ ៤ម៉ែត្រ រួចឲ្យដាក់គ្រឿងសស្ត្រាវុធក្នុងរណ្តៅនោះ ដើម្បីនឹងលោតទៅឲ្យជង់ស្លាប់ក្នុងរណ្តៅ តែនៅពេលមុននឹងលោតសម្លាប់ខ្លួននោះ សេនាមឿង បង្គាប់ឲ្យពួកពលរដ្ឋទាំងអស់មកស្តាប់ពាក្យឱវាទ លោកប្រកាសថា "សូមអស់លោកខំប្រឹងយកចិត្តទុកដាក់ក្នុងរឿងចម្បាំងពេលនេះ ដើម្បីរំដោះដែនដី ឲ្យបានរួចពីកណ្តាប់នៃបច្ចាមិត្តចំណែកខ្ញុំៗធានាខាងទ័ពខ្មោច សូមអស់លោកសង្ឃឹមទុកចុះ បើខ្ញុំស្លាប់ទៅបាន ៧ថ្ងៃ ឮសូរសន្ធឹកហ៊ោ

កព្រៀវបីដូចជាសំឡេងផ្គរលាន់ យើងនឹងមានជ័យហើយ ។ លុះផ្គាំរួចលោតចុះទៅក្នុងរណ្តៅព្រឹប ប្រពន្ធឃើញប្តីលោតដូច្នោះ ក៏លោតទៅជាមួយនឹងប្តីព្រមទាំងកូនប្រុសពីរនាក់ស្លាប់ជាមួយគ្នា ដល់ថ្ងៃជាគម្រប់ ៧ លាន់ឮសូរសន្ធឹកដូចកាលផ្គាំមែន ។

ទ័ពសៀមចូលដល់បាត់ដំបង ឆ្លងចូលមកដល់អូរមួយ សព្វថ្ងៃគេហៅថាអូរស្វាយដូនកែវ ជួបគ្នានឹងទ័ពជ័យអស្ចារ្យ ទ័ពខ្មោចចេញទៅមុនសម្តែងឫទ្ធិ ធ្វើឲ្យពលសៀមវិលមុខ ចុកពោះ ចុះក្អួតដួលខ្លួនឯងស្រួលៗ ទ័ពព្រះជ័យចេស្តាចូលទៅកាប់សម្លាប់អស់ ពួកកងទ័ព សៀមទប់ទល់មិនបាន ថយទៅដល់បាត់ដំបង ធ្វើសារទៅក្រាបទូលព្រះចៅតាមដំណើរសព្វគ្រប់ ព្រះចៅទ្រង់ជ្រាបឲ្យទ័ពថយត្រឡប់ទៅស្រុកសៀមវិញ ។

ចំណែកពួកកងទ័ពព្រះជ័យអស្ចារ្យ នាំគ្នាត្រឡប់មកកាន់បន្ទាយវិញ សព្វថ្ងៃគេហៅថាបន្ទាយជ័យ ។ ចាប់ដើមពីពេលនោះមក ព្រះជ័យអស្ចារ្យបានទទួលរាជាភិសេកសោយរាជ្យ និងទទួលនាមថាព្រះជ័យចេស្តាព្រះចៅក្រុងកម្ពុជាធិបតី គង់នៅបន្ទាយជ័យ ។ លុះព្រះអង្គបានឡើងសោយរាជ្យសម្បត្តិសុខសាន្តហើយ ទ្រង់នឹកឃើញដល់គុណូបការៈសេនាមឿង ដែលស៊ូប្តូរជីវិតចំពោះព្រះអង្គនិងចំពោះទឹកដីខ្មែរ ទ្រង់ក៏ចាត់ឲ្យធ្វើបុណ្យឧទ្ទិសផលដល់ដួងវិញ្ញាណខន្ធរបស់សេនាមឿង យ៉ាងឧឡារិកអស្ចារ្យ ជាប់ជាទំនៀមដរាបមកដល់មកសព្វថ្ងៃនេះ ហៅថាធ្វើបុណ្យឡើងអ្នកតាឃ្លាំង មឿង ទៅវិញ ។